ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំពិភាក្សាលើ "សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ក្នុងឆ្នាំ២០២១-២០២៣"

កាលពីព្រឹកថ្ងៃទី៨ ខែមករា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តម ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា IDP ក្នុងឆ្នាំ២០២១-២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.)។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីសំណាក់ **ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, **ឯកឧត្តម កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល, **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, **ឯកឧត្តម ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធជាសមាជិក គ.ស.ហ. ព្រមទាំងក្រុមការងារនៃលេខាធិការដ្ឋាន IDP សរុបប្រមាណ ៦០រូប។

គោលបំណងចម្បងៗនៃកិច្ចប្រជុំ រួមមាន៖ ទី១. ពិនិត្យ ពិភាក្សា និងផ្តល់ធាតុចូលលើសេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា IDP ក្នុងឆ្នាំ២០២១-២០២៣, ទី២. ពិនិត្យ និងផ្តល់អនុសាសន៍ជំរុញការអនុវត្តវិធានការដែលនៅសេសសល់និងមានភាពយឺតយ៉ាវ, និងទី៣. ផ្តល់អនុសាសន៍ណែនាំក្នុងការត្រៀមរៀបចំរបាយការណ៍វាយតម្លៃចុងអាណត្តិនៃការអនុវត្តគោលនយោបាយ IDP។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ប្រធានអង្គប្រជុំ បានសម្តែងសេចក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ឯកឧត្តមរដ្ឋមន្ត្រី

ឯកឧត្តម លោកជំទាវ តំណាងក្រសួងស្ថាប័នជាសមាជិក គ.ស.ហ. ដែលបានផ្តល់កិត្តិយស អញ្ជើញចូលរួម កិច្ចប្រជុំនាឱកាសនោះ និងបានជម្រាបជូនអំពីរបៀបវារៈ ក៏ដូចជាគោលបំណងសំខាន់ៗនៃការរៀបចំ កិច្ចប្រជុំខាងលើ។

ជាកិច្ចបន្ទាប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ** បានប្រគល់វេទិកាជូន **ឯកឧត្តម ស៊ុន ចាន់ថុល** ដើម្បីមានមតិ និងជម្រាបជូនអង្គប្រជុំអំពីការរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលបានអនុវត្តក្នុងឆ្នាំ២០២១-២០២៣ កន្លងមក ក្រោមការដឹកនាំសម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្នុងកិច្ចប្រជុំនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក.អ.ក.** ក៏បានគូសរំលេចពីចំណុចសំខាន់ៗមួយចំនួន រួមមាន៖ សារតារនៃការរៀបចំគោលនយោបាយ IDP ឆ្នាំ២០១៥-២០២៥, ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាដែលផ្តោតលើការជំរុញ កែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធ ឧស្សាហកម្ម ឧស្សាហកម្មអតិពលកម្មឱ្យឈានទៅរកឧស្សាហកម្មផ្អែកលើជំនាញ, ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ឆ្លើយតបទៅនឹងការប្រែប្រួលរចនាសម្ព័ន្ធ សេដ្ឋកិច្ចក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងសកល, ជាតុផ្សំសំខាន់ៗ ដែលជាកត្តាជំរុញឱ្យសម្រេចបាននូវចក្ខុវិស័យខាងលើ, វិធានការគោលនយោបាយសំខាន់ៗ ព្រមទាំងខ្លឹមសារ និងទម្រង់នៃសេចក្តីព្រាងរបាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣។

បន្ទាប់ពីមតិដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក.អ.ក.** ឯកឧត្តម **នុត អ៊ុនវណ្ណា** អគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា និងជាប្រធានលេខាធិការដ្ឋាន IDP នៃ ក.អ.ក. ក៏បានធ្វើបទបង្ហាញសង្ខេបស្តីពីរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តគោលនយោបាយ IDP ក្នុង ឆ្នាំ២០២១-២០២៣ រួមមាន ចំណុចសំខាន់ៗមួយចំនួន ដូចជា៖ ទី១. វដ្តនៃការជំរុញការអនុវត្ត IDP និង ការរៀបចំរបាយការណ៍វឌ្ឍនភាព, ទី២. រចនាសម្ព័ន្ធនៃរបាយការណ៍, ទី៣. វិធីសាស្ត្រនៃការតាមដានការ អនុវត្តគោលនយោបាយ IDP, ទី៤. ការតាមដានសមិទ្ធកម្ម, ទី៥. បញ្ហាប្រឈម និងហានិភ័យ និង ទី៦. សេចក្តីសន្និដ្ឋាន និងទិសដៅការងារបន្ត។

សរុបរួមមក កិច្ចប្រជុំខាងលើបានសម្តែងការកោតសរសើរនិងវាយតម្លៃខ្ពស់ដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា ដែលបានខិតខំសម្របសម្រួលនិងដឹកនាំរៀបចំរបាយការណ៍វឌ្ឍនភាពបានល្អនិងគ្រប់ជ្រុងជ្រោយ ហើយដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ IDP ក្នុងឆ្នាំ២០២១-២០២៣ ព្រមទាំង លទ្ធផលសម្រេចបាននិងការជំរុញអនុវត្តវិធានការនានា ខណៈពេលដែលកម្ពុជាបាននិងកំពុងជួបប្រទះ នឹងការរីករាលដាលនៃជំងឺ COVID-១៩ និងបញ្ហាប្រឈមជាច្រើននាពេលនោះ។ ជាមួយគ្នានេះ តាមរយៈ វឌ្ឍនភាពដែលសម្រេចបាន ក៏បានបង្ហាញផងដែរថា វិស័យឧស្សាហកម្មកម្ពុជាបាននិងកំពុងដើបឡើងគួរ ឱ្យកត់សម្គាល់ ពិសេសអនុវិស័យកម្មន្តសាល។ អង្គប្រជុំក៏បានចែករំលែកនូវព័ត៌មាន ជាតុចូល និងផ្តល់នូវ អនុសាសន៍សំខាន់ៗផងដែរ ក្នុងការត្រៀមគិតគូរសម្រាប់ការរៀបចំឯកសារគោលនយោបាយឧស្សាហកម្ម កម្ពុជាសម្រាប់ដំណាក់កាលបន្ទាប់ ពិសេសឆ្លើយតបទៅនឹងបរិការណ៍ប្រែប្រួលថ្មីៗដែលកើតមានឡើង។